# មេរៀនទី៣៨៖ ព្រះបញ្ជូនគ្រោះកាចនៅស្រុកអេហ្ស៊ីប

## និក្ខមនំ ៧៖៨ -១០៖២៩

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/zEPNjP0EypM

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/WzwlUneeMEw

**គោលបំណង៖** គ្មានអ្វីដែលមានអំណាចជាងព្រះទេ

**ខគម្ពីរចងចាំ៖ ភីលីព ៤៖១៣** *"ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ។"*

**ចំរៀង** ( *យូធូបលីង* )៖

១. ពេលខ្យល់ព្យុះបក់ខ្លាំង https://youtu.be/lI5A7jKQb2o
២. ព្រះអង្គទ្រង់អស្ចារ្យ t https://youtu.be/QXEVqO94wpg
៣. ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ https://youtu.be/I-PzUIJ0MVo

### ១. អធិស្ឋាន

### ២. ចំរៀង *សូមច្រៀងចម្រៀងដែលមានលីង នៅក្នុងយូធូបលីងខាងលើ*

### ៣. ល្បែងកំសាន្ត *"ល្បែងពត់ដៃ "*



ឲ្យកុមារចាប់ដៃគូរទៅតាមអាយុឬមាឌរបស់ពួកគេហើយឲ្យពួកគេចាប់ផ្តើម ពត់ដៃគ្នា អ្នកដែលមានកំលាំងខ្លាំងជាងគេគឺជាអ្នកឈ្នះ។ សូមរំលឹកកុមារថា ទោះបី ជាគេមានកំលាំងខ្លាំងជាងគេនៅក្នុងថ្នាក់ក៏ដោយ ក៏គេនៅតែមិនអាចខ្លាំងជាង អំណាចនៃព្រះបានដែរ។

### ៤. ការណែនាំមេរៀន

ព្រះទ្រង់មានអំណាចលើគ្រប់ទាំងអស់ នោះមានន័យថាទ្រង់ធំជាងបញ្ហារបស់យើង។ នៅពេលដែលក្នុងជីវិតរបស់យើងត្រូវការជំនួយ ទ្រង់នឹងជួយដល់យើង។ ពេលខ្លះជីវិតយើងអាចនឹងជួបទុក្ខលំបាកដូចគ្នា ដូចជាជនជាតិអ៊ីស្រាអែលដែរ ពួកគេបានធ្វើជាទាសកអស់រយៈជាង ៤០០ឆ្នាំ! ហើយពួកគេបានរង់ចាំអស់រយៈពេលយ៉ាងយូរ ដើម្បីអោយនរណាម្នាក់មកជួយពួកគេចេញពីការលំបាកនោះ។ ព្រះក៏បានបញ្ជូនម៉ូសេដើម្បីឲ្យទៅជួយពួកគេ។ ដោយសារតែគ្មានអ្វីអាចនឹងប្រៀបផ្ទឹមស្មើនឹងអំណាចរបស់ព្រះបានឡើយនោះ យើងអាចទុកចិត្តលើព្រះអង្គ ដើម្បីអោយទ្រង់ធ្វើការនៅក្នុងជីវិតរបស់យើងផងដែរ។ ព្រះអាចធ្វើឲ្យ

### ៥. រឿងនៅក្នុងព្រះគម្ពីរ

តើនរណាមានអំណាចធំជាងគេនៅក្នុងក្រុមគ្រួសាររបស់ប្អូន? តើអ្នកណាធំជាងគេនៅក្នុងប្រទេសរបស់យើង? តើនរណាមានអំណាចធំជាងគេនៅក្នុងភូមិរបស់យើង? ហើយតើនរណាមានអំណាចធំជាងគេនៅក្នុងសាលារបស់យើង? ផារ៉ោនដែលជាស្តេចរបស់អេហ្ស៊ីប គឺជាបុរសដែលមានអំណាចជាងគេ។ យ៉ាងណាមិញទាំងគាត់ និងឪពុកគាត់ពីដំណាមុនៗ បានទុកជនជាតិអ៊ីស្រាអែល ធ្វើជាទាសករអស់រយៈពេលជាង៤០០ឆ្នាំ។ វាត្រូវប្រើពេលវេលាយូរដើម្បីធ្វើអោយមនុស្សទាំងនោះស្តាប់បង្គាប់ និងត្រូវ

ឃ្លាំមើលពួកគេមិនឲ្យរត់គេចបានឡើយ។ ប៉ុន្តែព្រះចង់ជួយរំដោះជនជាតិអ៊ីស្រាអែល។ យើងដឹងថាព្រះទ្រង់មានអំណាច, តើប្អូនគិតថារវាងផារ៉ោន និងព្រះអ្នកណាមានអំណាចជាង? រឿងនៅព្រះគម្ពីរនៅថ្ងៃនេះប្រៀបដូចជាការ ប្រកួតប្រជែងរវាងផារ៉ោននិងព្រះអញ្ចឹង។ ព្រះបានធ្វើការអស្ចារ្យ ដើម្បីធ្វើយ៉ាងណាឲ្យផារ៉ោន ដោះលែងជនជាតិអ៊ីស្រាអែលឲ្យមានសេរីភាព។ ជំនួសឲ្យការជឿលើព្រះ ផារ៉ោនបានព្យាយាមផ្ចាញ់ផ្ចាល អំណាចរបស់ព្រះទៅវិញ។ ផារ៉ោនបានបញ្ជាអោយគ្រូអាបធ្មប់របស់ខ្លួនធ្វើត្រាប់តាម ការអស្ចារ្យរបស់ព្រះផងដែរ។ ប្រហែលជាមានប្អូនខ្លះមិនបានដឹងទេថាពួកគ្រូអាបធ្មប់ទាំងនោះអាចធ្វើបានមែន! សូមចងចាំថា ផារ៉ោនគឺជាបុរសខ្លាំងពូកែម្នាក់ មកពីគ្រួសារដែលមានអំណាច។

ចែកកុមារជាពីរក្រុម ក្រុមមួយនឹងគាំទ្រខាងផារ៉ោន ហើយក្រុមមួយទៀតនឹងគាំទ្រខាងព្រះ។ មិនថា នៅពេលណាដែលខាងផារ៉ោនឬ ព្រះទទួល បានជោគជ័យក្នុងការបង្ហាញការអស្ចារ្យកុមារម្នាក់ត្រូវក្រោកឈរឡើង។ នៅចុងបញ្ចប់នៃសាច់រឿង ក្រុមដែលមានកុមារឈរច្រើនជាងគេគឺជាក្រុមដែលឈ្នះ! ត្រៀមខ្លួនហើយឬនៅ?

- ម៉ូសេបានបោះដំបងទៅលើដី ហើយវាបានក្លាយទៅជាសត្វពស់! ឲ្យកុមារម្នាក់ក្នុងក្រុមដែលគាំទ្រ "ព្រះ" ងើបឈរឡើង
- គ្រូអាបធ្មប់របស់ផារ៉ោនបានធ្វើឲ្យដំបងឈើក្លាយទៅជាសត្វពស់។ ឲ្យកុមារម្នាក់ក្នុងក្រុមដែលគាំ-ទ្រ " ផារ៉ោន" ងើបឈរឡើង
- សត្វពស់របស់ម៉ូសេលេបសត្វពស់របស់ផារ៉ោន។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង
- ព្រះបានធ្វើឲ្យទឹកក្លាយទៅជាឈាម។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង
- គ្រូអាបធ្មប់របស់ផារ៉ោនបានធ្វើឲ្យទឹកក្លាយទៅជាឈាម។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ផារ៉ោន" ងើបឈរឡើង
- ព្រះបានធ្វើឱ្យកង្កែបរាប់ពាន់ក្បាលលោតចុះលោតឡើងគ្រប់ទីកន្លែង។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង
- គ្រូអាបធ្មប់បានធ្វើឱ្យមានកង្កែបជាច្រើនចេញមក។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ផារ៉ោន" ងើបឈរឡើង
- ព្រះបានប្រែក្លាយធូលីដីទៅជាសត្វល្អិត។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង
- គ្រូអាបធ្មប់បានព្យាយាមប្រែក្លាយធូលីដីទៅជាសត្វល្អិតប៉ុន្តែពួកគេមិនអាចធ្វើបានទេ។ គ្រូអាបធ្មប់ នោះបានប្រាប់ផារ៉ោនអោយបោះបង់និងឲ្យគាត់ជឿលើព្រះទៅ។ ឲ្យកុមារម្នាក់នៅក្នុងក្រុមរបស់ "ផារ៉ោន" អង្គុយចុះ។
- ព្រះបានធ្វើឱ្យរុយរាប់ពាន់ក្បាលលេចឡើងនៅគ្រប់ទីកន្លែង។ សត្វរុយទាំងអស់នោះរំខានផារ៉ោននិងជនជាតិអេហ្ស៊ីបយ៉ាងខ្លាំងប៉ុន្តែវាមិនរំខានដល់ប្រជារាស្ត្ររបស់ព្រះទេ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង។
- ព្រះបានបង្កើតភាពងងឹតអស់រយៈពេលបីថ្ងៃ ដោយគ្មានព្រះអាទិត្យព្រះច័ន្ទឬផ្កាយឡើយ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ព្រះ" ងើបឈរឡើង។

- គ្រូអាបធ្មប់ទាំងនោះឈប់ព្យាយាមធ្វើតាមផារ៉ោនបញ្ជា ព្រោះពួកគេមើលអ្វីមិនឃើញទៀតទេ! ពួកគេបានបោះបង់ការចង់ធ្វើខ្លួនឲ្យដូចជាព្រះហើយ។ ឲ្យកុមារម្នាក់ក្នុងក្រុមរបស់ "ផារ៉ោន" អង្គុយចុះ។

តើក្រុមណាជាអ្នកឈ្នះ? ចាស៎/បាទ ក្រុមគាំទ្រព្រះជាអ្នកឈ្នះ! ព្រះអង្គឈ្នះព្រោះគ្មានអ្វីដែលមានអំណាចធំជាងព្រះនោះទេ។ ព្រះបានរំដោះជនជាតិអ៊ីស្រាអែលពីផារ៉ោន!

**៦. សំនួរពិភាក្សា**

១. តើជនជាតិអ៊ីស្រាអែលជាប់ជាទាសករនៅប្រទេសអេហ្ស៊ីបអស់រយៈពេលប៉ុន្មានឆ្នាំ? (*៤០០ឆ្នាំ*)

២. តើព្រះចង់ធ្វើអ្វីដើម្បីជនជាតិអ៊ីស្រាអែល? (*ទ្រង់ចង់ដោះលែងពួកគេពីភាពជាទាសករ*)

៣. រវាងព្រះ និងផារ៉ោន តើនរណាមានអំណាចធំជាង? (*ព្រះ*)

៤. តើប្អូនគួរធ្វើដូចម្តេចនៅពេលប្អូនត្រូវការជំនួយនៅក្នុងជីវិត? (*ទូលសូមព្រះ ព្រោះគ្មានអ្វីដែលមានអំណាចជាងព្រះទេ*)

**៨. ខគម្ពីរចងចាំ**

**ភីលីព ៤៖១៣** *"ខ្ញុំអាចនឹងធ្វើគ្រប់ទាំងអស់បាន ដោយសារព្រះគ្រីស្ទដែលទ្រង់ចំរើន កំឡាំងដល់ខ្ញុំ។"*

(*សូមជួយកុមារឲ្យចងចាំខគម្ពីរនេះ*)



**៩. ហត្ថកម្ម** **"ព្រះជាទីមួយ"**





កាត់រូបប្រអប់ដៃពីរសំរាប់កុមារម្នាក់ៗ ហើយយកការមកបិតគែមៗនៃប្រអប់ដៃ ទាំង២នោះឲ្យជាប់គ្នា(ធ្វើយ៉ាណាអាចដាក់ប្រអប់ដៃ ម្ខាងចូលបាន)។ សូមសរសេរពាក្យ ថា "ព្រះជាទីមួយ" នៅលើដៃនោះ។ យករូបដៃ នោះមកស៊កក្នុងដៃរបស់កុមារ ហើយឲ្យកុមារទាំងអស់គ្នា និយាយថា "ព្រះជាទីមួយ" ។

**១០. ចំរៀង** សូមច្រៀងចម្រៀង៖ គ្រប់ទាំងអស់ខ្ញុំអាចធ្វើបាន

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ**: (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)
មនុស្សគ្រប់រូបត្រូវការជំនួយ និងអំណាចពីព្រះដើម្បីជួយឲ្យពួកគេជម្នះការលំបាកក្នុងការរស់នៅលើផែនដីនេះ។ ព្រះយេស៊ូវផ្តល់អំណាចដល់អ្នកដើរតាមទ្រង់ ហើយជួយមិត្តសម្លាញ់របស់ទ្រង់! ហេតុអ្វីបានជាព្រះអនុញ្ញាតអោយអំពើអាក្រក់រីកដុះដាល? យើងដឹងថាព្រះមានអំណាចដើម្បីបញ្ឈប់ការអាក្រក់ហើយទ្រង់ជួយដល់ជនស្លូតត្រង់។ តើអ្នកនឹងទុកចិត្តដល់ពេលវេលារបស់ព្រះដែរឬទេ ហើយតើអ្នកអាចនឹងរង់ចាំអំណាចរបស់ព្រះអោយមកដែរឬទេ? វាជាការលំបាកសំរាប់គ្រីស្ទបរិស័ទជាច្រើន។ សូមយកពេល

នេះ ដើម្បីអធិស្ឋានតាមការអធិស្ឋាននេះ "អរគុណព្រះយេស៊ូវដែលបានជួយដល់កូនដោយអំណាច របស់ទ្រង់។ សូមផ្តល់ភាពក្លាហានដល់កូននៅពេលដែលកូនរង់ចាំព្រះអង្គធ្វើការ" ។

